# LYNN PUBLIC SCHOOLS

James Leo McGuinness អគាររដ្ឋបាល – 100 Bennett Street, Lynn, MA 01905
ទូរសព្ទ (781) 593-1680 ~ ទូរសារ (781) 477-7487

*Patrick A. Tutwiler, PhD*
*នាយកសាលាប្រចាំមណ្ឌល*

ខែមីនាឆ្នាំ 2020

ជូនចំពោះក្រុមគ្រួសារ Lynn ជាទីគោរពរាប់អាន

នាយកដ្ឋានសាលារៀន Lynn (Lynn School Department) និងផ្នែកសុខភាពសាធារណៈទីក្រុង Lynn (City of Lynn Public Health Division) កំពុងធ្វើការទំនាក់ទំនង និងធ្វើការជាមួយនាយកដ្ឋានសុខភាពសាធារណៈរបស់រដ្ឋ Massachusetts (Massachusetts Department of Public Health) ទាក់ទងនឹងមេរោគកូរ៉ូនា។ បច្ចុប្បន្នភាពប្រចាំថ្ងៃត្រូវបានផ្តល់ឲ្យយើងពីនាយកដ្ឋានសុខភាពសាធារណៈរបស់រដ្ឋ Massachusetts ហើយយើងចង់ធានាជាថ្មីដល់អ្នកថា ហានិភ័យផ្ទាល់ ចំពោះសាធារណជនទូទៅគឺមានកម្រិតទាប។

មជ្ឈមណ្ឌលគ្រប់គ្រងជំងឺ (Center for Disease Control; CDC) បានចេញការណែនាំអំពាវនាវឲ្យបុគ្គលដែលបានត្រឡប់មកពីបណ្តាប្រទេសដែលមានការឆ្លងមេរោគយ៉ាងទូលំទូលាយ និងកំពុងបន្តកាលពីពេលថ្មីៗឲ្យស្ថិតនៅដាច់ពីគេដោយខ្លួនឯងរយៈពេល 14 ថ្ងៃគិតចាប់ពីថ្ងៃដែលគេបានចាកចេញពីប្រទេសដែលបានកំណត់នោះ។ ប្រទេសទាំងនោះមានដូចជា៖ ចិន អ៊ីតាលី អ៊ីរ៉ង់ និងកូរ៉េខាងត្បូង។ បើសិនជាអ្នកបានចាកចេញពីប្រទេសណាមួយក្នុងចំណោមប្រទេសដែលបានកំណត់នៅថ្ងៃ ឬបន្ទាប់ពីថ្ងៃទី 22 ខែកុម្ភៈឆ្នាំ 2020 ខ្ញុំសូមស្នើឲ្យអ្នកជូនដំណឹងដល់នាយកសាលារបស់សិស្សអ្នកឲ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន។ បន្ទាប់មក តាមការណែនាំរបស់ CDC អ្នកត្រូវតែស្ថិតនៅដាច់ពីគេដោយខ្លួនឯងរយៈពេលសរុប 14 ថ្ងៃគិតចាប់ពីថ្ងៃចាកចេញពីប្រទេសដែលបានកំណត់។

ដូចសព្វមួយដង ការប្រុងប្រយ័ត្នជាមុនសាមញ្ញៗនឹងជួយបង្ការការរីករាលដាលនៃជំងឺគ្រុនផ្តាសាយធំ និងជំងឺផ្លូវដង្ហើមផ្សេងៗទៀត៖

- គ្របមាត់របស់អ្នកនៅពេលអ្នកក្អក ឬកណ្តាស់ ដោយប្រើក្រដាសជូតមាត់ ឬផ្នែកខាងក្នុងនៃកែងដៃរបស់អ្នក
- លាងសម្អាតដៃរបស់អ្នក 20 វិនាទីជាមួយសាប៊ូ និងទឹកក្តៅឧ៉ុនៗឲ្យបានញឹកញាប់ និងប្រើទឹកអនាម័យលាងដៃ
- បើសិនជាអ្នកមានអាការៈគ្រុនក្តៅ ឬមិនស្រួលខ្លួន ចូរស្ថិតនៅផ្ទះ និងហៅទូរសព្ទទៅអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក
- បើសិនជាកូនរបស់អ្នកមានអាការៈគ្រុនក្តៅ គេមិនគួរត្រឡប់ទៅសាលារៀនវិញទេ រហូតទាល់តែគេលែងមានអាការៈគ្រុនក្តៅរយៈពេល 24 ម៉ោងដោយមិនប្រើថ្នាំបញ្ចុះកម្តៅ។
- ចាក់វ៉ាក់សាំងជំងឺគ្រុនផ្តាសាយធំ – វាមិនទាន់យឺតពេលទេ! រកមើលព័ត៌មានបន្ថែមអំពីជំងឺគ្រុនផ្តាសាយធំ និងទីកន្លែងទទួលវ៉ាក់សាំងជំងឺគ្រុនផ្តាសាយធំនៅទីនេះ៖ https://www.mass.gov/info-details/what-should-i-know-about-flu

មេរោគកូរ៉ូណា គឺជាស្ថានការណ៍ដែលកំពុងវិវឌ្ឍមួយ ដែលយើងកំពុងតាមដានយ៉ាងយកចិត្តទុកដាក់។ សូមទុកចិត្តចុះថា យើងកំពុងតាមដានក្តីកង្វល់អំពីសុខភាពសិស្ស។ លើសពីនេះ នាយកដ្ឋានសេវាកម្មអធិការកិច្ច (Inspectional Services Department) កំពុងធ្វើការសម្លាប់មេរោគនៅក្នុងសាលារៀនដូចដែលពួកគេធ្វើជាធម្មតានៅក្នុងអំឡុងរដូវជំងឺផ្តាសាយ និងជំងឺផ្តាសាយធំ និងកំពុងសម្លាប់មេរោគនៅលើតំបន់ដែល "ប៉ះពាល់ច្រើន" (ដៃទ្វារ ដៃករុញលើទ្វារ បង្កាន់ដៃ ។ល។) ជាផ្នែកមួយនៃពិធីការសម្អាតប្រចាំថ្ងៃរបស់ពួកគេ។ យើងកំពុងអនុវត្តតាមការណែនាំទាំងអស់ ដើម្បីធានាបាននូវសុវត្ថិភាពរបស់សិស្ស និងបុគ្គលិករបស់យើង។

យើងនៅតែប្តេជ្ញាខ្ពស់ចំពោះភាពសុខសប្បាយរបស់សិស្ស និងបុគ្គលិក ហើយនឹងបន្តចែករំលែកព័ត៌មានថ្មីជាមួយអ្នកតាមការចាំបាច់។ សូមចូលទៅកាន់គេហទំព័ររបស់មជ្ឈមណ្ឌលគ្រប់គ្រងជំងឺ (https://www.cdc.gov/coronavirus) សម្រាប់ព័ត៌មានបន្ថែម។ យើងក៏នឹងផ្តល់ព័ត៌មានថ្មីៗនៅលើ www.lynnschools.org និងទំព័រ Facebook របស់យើងផងដែរ។

ដោយក្តីគោរព

Patrick Tutwiler, PhD
នាយកសាលាប្រចាំមណ្ឌល